ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់

និងប្រព័ន្ធយុត្តិធម៌

អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍

# របាយការណ៍

## កិច្ចប្រជុំតាមដានការរៀបចំស្តីពីប្រព័ន្ធសូចនាករ

ឆ្នាំពីរពាន់ប្រាំពីរ ខែ ឧសភា ថ្ងៃទី ម្ភៃមួយ វេលាម៉ោងពីរ និងសាមសិបនាទី នៅសាលប្រជុំរបស់ក្រុមប្រឹក្សា កំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ មានរៀបចំកិច្ចប្រជុំមួយក្រោមអធិបតីភាពរបស់ ឯកឧត្តម **ស៊ុំ ម៉ានិត** ប្រធានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ដើម្បីពិនិត្យ និងពិភាក្សាអំពីការរៀបចំប្រពន្ធ័ សូចនាករតាមដានការអនុវត្តកំណែទម្រង់ច្បាប់ និងតុលាការ ។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់មកជាមួយ ។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម **ស៊ុំ ម៉ានិត** បានសម្តែងការស្វាគមន៍ចំពោះអង្គប្រជុំ និងធ្វើការរំលឹកអំពីដំណើរការ នៃការរៀបចំប្រព័ន្ធសូចនាករតាមដានការអនុវត្តកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ។ ជាបន្ទាប់ឯកឧត្តម ស៊ុយ ម៉ុងលាង បានលើកឡើងពីការជួបប្រជុំជាមួយនឹងអង្គការប្រទេសផ្តល់ជំនួយនៅថ្ងៃទី **២៦ ខែ ឧសភា ឆ្នាំ ២០០៧ ខាង មុខនេះ ។**

ក្នុងរបៀបវារៈជាបន្ទាប់. លោក Bent Vase និងលោក Eic Andre Anderson បានធ្វើការពន្យល់អំពីការ រៀបចំប្រព័ន្ធសូចនាករតាមដានការអនុវត្តកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ តាមរយៈការបញ្ចាំងស្លាយ ដែលមានដូច ជូនភ្ជាប់មកជាមួយ ។

ក្នុងរបៀបវារៈ សំណួរ ចម្លើយ ឯកឧត្តម **ស៊ុយ ម៉ុងលាង** នាយកអង្គភាពគ្រប់គ្រងគម្រោងបានមានប្រសាសន៍ថា កាលពីកិច្ចប្រជុំគណៈកម្មការសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងប្រទេសផ្តល់ជំនួយ (GDCC) ក៏មានលើកឡើងពីការ ត្រូវបង្កើតប្រព័ន្ធសូចនាករនេះដែរ ដោយក្រុមការងារបច្ចេកទេសចម្រុះៗ ចំណែកខាងអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ក៏មាន អញ្ជើញលោក Livingston (UNDP) មកធ្វើបទបង្ហាញស្តីពីប្រព័ន្ធសូចនាករកំណែទម្រង់ច្បាប់ម្តងដែរៗ អ្វីដែលសំខាន់ក្នុងការ ប្រជុំថ្ងៃនេះ គឺការងារដែលត្រូវធ្វើជាបន្តដើម្បីរៀបចំគម្រោងនេះ ។

ដាក់ស្តែងអង្គភាពគ្រប់គ្រងគម្រោង ជាអ្នកទទួលបន្ទុករៀបចំគម្រោង រៀបចំក្រុមការងារបច្ចេកទេសសម្រាប់គម្រោង។

ឯកឧត្តម **ស៊ុំ ម៉ានិត** បានមានប្រសាសន៍ថា ការរៀបចំសូចនាករនេះមានប្រយោជន៍ណាស់ ប៉ុន្តែគឺជាកាំបិត មុខពីរ ។ វាមានប្រយោជន៍ចំពោះរាជរដ្ឋាភិបាល ភ្នាក់ងារអ្នកអនុវត្ត និងម្ចាស់ជំនួយ ដែលចង់ឃើញលទ្ធផលនៃការកែទម្រង់ច្បាប់ និង ប្រព័ន្ធតុលាការ តើដើរដល់កំរិតណា ហើយអនុវត្តដល់ណា ព្រមទាំងបង្ហាញពីលទ្ធផលដែលធ្វើបាន និងលទ្ធផលដែលធ្វើមិនបាន ដូច្នេះយើងត្រូវតែប្រឹងប្រែងឡើងទើបបាន។ អង្គភាពគ្រប់គ្រងគម្រោងនឹងរៀបចំក្រុមការងារបច្ចេកទេស ដើម្បីរៀបចំប្រព័ន្ធ សូចនាករនេះ។

ដោយសង្កេតឃើញថា អង្គប្រជុំហាក់ដូចជាពុំសូវយល់ច្បាស់អំពីការពន្យល់របស់អ្នកបច្ចេកទេស DIHR អំពីប្រព័ន្ធ សូចនាករនេះ ឯកឧត្តម **ស៊ុំ ម៉ានិត** បានស្នើឱ្យឯកឧត្តម **ស៊ុយ ម៉ុងលាង** រៀបចំធ្វើការបកប្រែឯកសារជាភាសាខ្មែរ ហើយ អញ្ជើញតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ ជួបប្រជុំម្តងទៀត ដើម្បីស្វែងយល់ពីបញ្ហានេះឱ្យកាន់តែច្បាស់។

ឯកឧត្តម **ហង់វ៉ូ រ៉ាកេន** អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ បានមានប្រសាសន៍ថា យើងគួរតាមដានមើលលទ្ធផលដែល ធ្វើបានហើយ និងលើអ្វីដែលមិនទាន់ធ្វើបានដែរ។ ឯកឧត្តមបន្តទៀតថា គួររៀបចំរចនាសម្ព័ន្ធតាមតុលាការនីមួយៗឱ្យរួចរាល់សិន សឹមធ្វើការតាមដានជាក្រោយនោះទើបបានលទ្ធផលល្អ។

ឯកឧត្តម **ទេព ដារ៉ុង** ប្រធានរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការបានមានប្រសាសន៍ថា យើងចង់ឱ្យមានប្រព័ន្ធសូចនាករ ស្តង់ដារ តែការអនុវត្តឱ្យបានគ្រប់តុលាការនោះមានការលំបាកណាស់ ព្រោះវាមានបរិបទខុសគ្នាដូចជា តុលាការខេត្តកណ្តាល មិន ដូចតុលាការក្រុងភ្នំពេញទេ ។

ឯកឧត្តម **ស៊ុយ ម៉ុងលាង** បានបញ្ជាក់ថា គម្រោងធ្វើសូចនាករនេះ អាចធ្វើបានពីរយ៉ាង គឺ ៖

១-អាចធ្វើតាមក្រសួងស្ថាប័ននីមួយៗ ដោយមិនបាច់មានថវិកាជំនួយនោះគឺ សូចនាករតាមដានការអនុវត្តកម្មវិធីសកម្ម ភាពកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌

២-បើធ្វើការតាមដានលទ្ធផលលើការកែទម្រង់ទាំងមូលនោះ គឺមានការពិបាកខ្លាំងណាស់។ គម្រោងនេះត្រូវ ការថវិកា ច្រើន ហើយត្រូវការការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់បន្ថែមទៀត

ជាមួយស្ថាប័នពាក់ព័ន្ធ ដែលគួរអភិវឌ្ឍន៍ផ្សេងៗ ដែល ពាក់ព័ន្ធ និងជាពិសេសធ្វើការស្តាបស្ទង់មតលើផលប៉ះពាល់ នៃកំណែទម្រង់លើសង្គមជាតទាំងមូលទៀតផង។

អង្គប្រជុំពិភាក្សាបានបញ្ចប់នៅវេលាម៉ោងប្រាំល្ងាចនាថ្ងៃដដែល ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៧*

**បានឃើញ និងឯកភាព**

ប្រធានអង្គប្រជុំ អ្នកកត់ត្រា

ស៊ុំ ម៉ានិត សេង រ៉ាន់ដា ស៊ុន សិរីវុធ

បញ្ជីឈ្មោះសមាសភាពចូលរួមក្នុងកិច្ចប្រជុំពិភាក្សា

នាថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៧

១ ឯកឧត្តម ស៊ុំ ម៉ានិត ប្រធានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍

២ ឯកឧត្តម ហង់ រ៉ូវ៉ាកេន អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍

៣ ឯកឧត្តម ទេព ដារ៉ុង ប្រធានរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

៤ លោក អ៊ុក សាវុធ ព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ

៥ ឯកឧត្តម ស៊ុយ ម៉ុងលាង នាយកអង្គភាពគ្រប់គ្រងគម្រោង

៦ ឯកឧត្តម ស្នួង លាងហៃ នាយករងអង្គភាពគ្រប់គ្រងគម្រោង

៧ ឯកឧត្តម ប៉ែន ប៊ុនឈា នាយករងអង្គភាពគ្រប់គ្រងគម្រោង

៨ ឯកឧត្តម ផៃ សុខខេង ប្រធានក្រុមគម្រោងកំណែទម្រង់តុលាការ

៩ ឯកឧត្តម នុត សារអាន រដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាប្រធានក្រុមការងារក.ក.ច.ន.យ

១០ ឯកឧត្តម អ៊ី ជន រដ្ឋលេខាធិការក្រសួងយុត្តិធម៌

១១ ឯកឧត្តម ប្រុក សារឿន ប្រធាននីតកម្មក្រសួងមហាផ្ទៃ

១២ លោក សេង ស៊ីវុត្ថា តំណាងមកពីសាលាឧទ្ធរណ៍

១៣ លោក បួន សុមុនី ប្រធានក្រុមគម្រោងរដ្ឋបាល និងហិរញ្ញវត្ថុ

១៤ លោក គង់ ផល្លៈ អនុប្រធានក្រុមកំណែទម្រង់ច្បាប់

១៥ លោក ឡុង ម៉ាមីឌី ការិយាល័យនីតិកម្ម ក្រសួងអប់រំ និងយុវជនកីឡា

១៦ កញ្ញា ហ៊ួង សុគុល អនុប្រធានក្រុមគម្រោងរដ្ឋបាល និងហិរញ្ញវត្ថុ

១៧ លោកស្រី ស្រី ប៊ុណ្ណារ័ត្ន អនុប្រធានក្រុមគម្រោងបណ្ណសារ និងព័ត៌មានវិទ្យា

១៨ លោក ជឹង ផេងស្រួយ ប្រធានក្រុមគម្រោងបណ្ណសារ និងព័ត៌មានវិទ្យា

១៩ លោក ឆែ លី អនុប្រធានក្រុមគម្រោងកំណែទម្រង់តុលាការ

២០ លោក ស៊ុន សិរីវុធ មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ

២១ តំណាងមកពីតុលាការកំពូល

២២ លោក រស់ ដាវុធ តំណាងមកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

២៣ Mr. Thomas Trier, DIHR

២៤ Mr. Phok Phira, Jica

២៥ Mr. Michael Engquist (Consultant) Danida

២៦ Mr. livingston Armytage (Senior Consul) UNDP

២៧ Mr. Ben Schultz, Adviser (CCJAP III)

២៨ Mrs. Kathryn Elliott (Second Secretary Development Cooperation) Australian Embassy

២៩ Mr. Ros Chhay (Senior Program Officer) Australian Embassy

៣០ Mr. Eic Andre Anderson, DIHR

៣១ Mr.Chor Siek Veng, Program Officer CCJAP

៣២ Mr. Rajan Shah (Access to Justice Advisor) EWMI

៣៣ Mr.Bent Vase, DIHR